អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C

# សត្វស្វាទាំងប្រាំនិងដើមចេក

## Five Monkeys and the Banana Tree



សូមស្កេនQR Code

កំន្សូរជីវចល

ធនធានបង្រៀន

**Written by Teacher Robin**

**Illustrated by Sem Rasin**



នៅក្នុងព្រៃជ្រៅមួយ មានដើមចេកមួយគុម្ពដុះត្រួងត្រាងស្លឹកតូចធំពណ៌បៃតងខៀវស្រងាត់។ មានសត្វស្វាប្រាំក្បាលកំពុងប្រឡែងគ្នាលេងនៅក្បែរនោះ។ សុខ៉ា សុខរី វីណា ដារ៉ូនិងដាលីស ជាឈ្មោះរបស់ពួកវា។ ពួកវាទាំងអស់គ្នាចូលចិត្តស៊ីចេកខ្លាំងណាស់។

អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C



ថ្ងៃមួយ ពួកគេបានឃើញផ្លែចេកមួយស្ទងនៅលើដើម។ «មើលហ្ន៎! ផ្លែចេកនោះទុំពណ៌លឿង ថ្លោសៗល្អណាស់!» វីណាបានស្រែកប្រាប់សត្វស្វាឯទៀត។
«តស់! បេះផ្លែចេក!» ដារ៉ូនិយាយ។



ពួកវាបានស្រែក ហើយប្រកែកគ្នា។

«ខ្ញុំចង់បេះមួយផ្លែដែលធំជាងគេ!» សុខរីនិយាយទាំងលោតចុះ លោតឡើង។

«តែខ្ញុំចង់បេះមុន!» ដារ៉ូស្រែកបណ្ដើរ ជ្រែងចង្កេះបណ្ដើរ។

«អត់ទេៗ! ឱ្យខ្ញុំបេះមុន!» ដាលីសស្រែក ឆ្គារដៃឆ្គារជើង ។

«អត់ទេៗ! ទុកឱ្យខ្ញុំជាអ្នកបេះមុនវិញ!» វីណាក៏ស្រែកដែរ។

អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C



សុខា៉ បានស្រែកខ្លាំងៗ «ពួកយើងឈប់ប្រកែកគ្នាទៅ! ពួកយើងត្រូវតែសហការគ្នា ដើម្បីបេះវាឱ្យបាន។ ខ្ញុំនឹងឡើងទៅលើដើមចេក ហើយអ្នកទាំងអស់គ្នាព្យាយាមទាញវាឱ្យទ្រេតចុះមកក្រោម»។ និយាយរួច សុខា៉បានឡើងចាប់ទាញស្នួងចេកទម្រេតចុះមក តាមកម្លាំងដែលអាចធ្វើទៅបាន ប៉ុន្តែដើមចេករឹងមាំណាស់ មិនព្រមទ្រេតចុះមកក្រោមនោះទេ។





«វីណា! ជួយខ្ញុំផង!» សុខា៉ស្រែក។ វីណាបានឡើងតោងទាញ សុខា៉ ពួកវាទាញហើយទាញទៀត
ប៉ុន្តែដើមចេកគ្រាន់តែរង្គើរមិនព្រមទ្រេតចុះមកក្រោមដដែល។
«ដារ៉ូ! មកជួយពួកយើងផង!» វីណាស្រែក។
ដារ៉ូបានឡើងតោងទាញ វីណា ពួកវាទាញហើយទាញទៀត
ប៉ុន្តែដើមចេកគ្រាន់តែរង្គើរមិនព្រមទ្រេតចុះមកក្រោមសោះ។





«ដាលីស! មកជួយពួកយើងផង!» ដារ៉ូស្រែក។

ដាលីស លោតឡើងតោងទាញ ដារ៉ូ ពួកវាទាញហើយទាញទៀត ប៉ុន្តែដើមចេកគ្រាន់តែរង្គើមិនព្រមទ្រេតចុះមកក្រោមឡើយ។ «សុខរី! ពួកយើងត្រូវការឯងជួយ!» ដាលីសស្រែក។ សុខរី លោតតោងទាញ ដាលីសយ៉ាងណែន ពួកវាទាញហើយទាញទៀត។ ឥឡូវនេះ សត្វស្វាទាំងប្រាំក្បាលបានតោងគ្នាជាជួរនៅលើស្ទងចេក

«ត្រៀមខ្លួនហើយឬនៅ?» សុខរ៉ាស្រែក។

«មួយ... ពីរ... បី... ទាញទាំងអស់គ្នា!»



ប្រិប! ប្រិប! ប្រិប!

ដើមចេកចាប់ផ្ដើមទ្រេតម្ដងបន្តិចៗ ហើយដួលលើដីតែម្ដង! គ្រាំង!

សត្វស្វាទាំងប្រាំក្បាលនាំគ្នាលោតចេញ។



«ហ៊ូហ៊ូ ហេហេ!» សត្វស្វាស្រែកហ៊ោកញ្ជ្រៀវ ។
ពួកវាបានដណ្តើមគ្នាបេះផ្លែចេកចេញពីស្នូង។
ឈប់សិន! ឈប់សិន!  សុខរ៉ាស្រែក។
«ពួកយើងត្រូវរាប់ផ្លែចេកទុំពណ៌លឿងមានប៉ុន្មានផ្លែ រួចចែកគ្នាស៊ី។»



«មួយ ពីរ បី បួន ប្រាំ ប្រាំមួយ ប្រាំពីរ ប្រាំបី ប្រាំបួន ដប់!»

សត្វស្វាបានរាប់ផ្លែចេកណាដែលទុំពណ៌លឿងចែកគ្នាម្តងមួយៗរហូតទាល់តែអស់។

«ចេកមួយផ្លែសម្រាប់សុខរី មួយផ្លែសម្រាប់វីណា មួយផ្លែសម្រាប់ដារ៉ូ  ឯមួយផ្លែទៀតសម្រាប់ដាលីស ហើយមួយផ្លែសម្រាប់ខ្ញុំ» សុខរ៉ាបាននិយាយ។ ពួកវាបានចែកនិងបកសម្បក ហើយស៊ីជាមួយគ្នារហូតអស់តែម្តង។

«ឆ្ងាញ់ណាស់! ឆ្ងាញ់ណាស់! ឆ្ងាញ់ណាស់!» សត្វស្វាទាំងប្រាំក្បាលបានស៊ីផ្លែចេកឡើងឆ្អែតដេកអេះពោះ។

«ផ្អែមណាស់! ឆ្ងាញ់ណាស់!» ពួកវាបាននិយាយ។



សត្វស្វាទាំងប្រាំបានឱបគ្នាយ៉ាងស្និទ្ធស្នាល។ ពួកវាបានទះដៃទាំងសងខាងជាមួយគ្នាទៅវិញទៅមកជាសញ្ញានៃភាពសាមគ្គីគ្នា។ ការចេះចែករំលែកធ្វើឱ្យចិត្តសប្បាយរីករាយ។ ឥឡូវនេះសត្វស្វាទាំងប្រាំដឹងហើយថា៖

ការចែករំលែកគឺល្អ។

ការចែករំលែកគឺសប្បាយរីករាយ។

ការចែករំលែកគឺរក្សាចំណងមិត្តភាព។